**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩២ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃអគ្គលេខាធិការដ្ឋាន ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល នៃអគ្គនាយកដ្ឋានថវិកា ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

### ផ្នែកទី ១
### អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍

**មាត្រា ២.-**

អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកកម្មដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍នានា ។

**មាត្រា ៣.-**

អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍មានភារកិច្ចដូចតទៅ:

- អនុវត្តតាមការណែនាំ ការបញ្ជា និងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍នានា
- ដឹកនាំការអនុវត្តការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍នានា ទាំងចំពោះគម្រោងវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល និងគម្រោងវិនិយោគឯកជនដែលអនុវត្តក្នុងក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងតម្រូវការនៃការអភិវឌ្ឍន៍ជាតិ និងដែលតម្រូវឱ្យមានការធ្វើលទ្ធកម្មដី សិទ្ធិ និងទ្រព្យសម្បត្តិផ្សេងៗ សម្រាប់បម្រើឱ្យការអនុវត្តគម្រោង
- ចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងារសិក្សាសមិទ្ធិលទ្ធភាពគម្រោង និងការងាររៀបចំគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ដើម្បីវាយតម្លៃ និងកាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គមសំដៅរួមចំណែកកាត់បន្ថយបន្ទុកចំណាយរបស់រាជរដ្ឋាភិបាលលើការងារដោះស្រាយផលប៉ះពាល់ និងកាត់បន្ថយបញ្ហាប្រឈមនានាឱ្យនៅកម្រិតអប្បបរមាក្នុងដំណាក់កាលអនុវត្តគម្រោង
- រៀបចំផែនសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍

- ពិនិត្យ និងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរៀបចំសំណើសុំការអនុម័តលើផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍
- ពិនិត្យ និងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើឯកសារគតិយុត្តផ្សេងៗរបស់គម្រោងដែលមានការពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់ និងការធ្វើលទ្ធកម្មដីសម្រាប់បម្រើឱ្យការអនុវត្តគម្រោង
- ចូលរួមចរចាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានរបស់រដ្ឋជាមួយដៃគូអភិវឌ្ឍន៍នានា ចំពោះផ្នែកដែលពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម និងការធ្វើលទ្ធកម្មដីសម្រាប់គម្រោង
- រៀបចំក្រុមការងារតាមតម្រូវការចាំបាច់ជាក់ស្តែង ផ្អែកលើសំណើបច្ចេកទេសរបស់ក្រសួង ស្ថាប័នអនុវត្តគម្រោង ដើម្បីចុះធ្វើការអង្កេតវាស់វែងលម្អិត និងវាយតម្លៃអំពីផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យមានការធ្វើលទ្ធកម្មដី សំណង់ផ្ទះសម្បែង សិទ្ធិ និងទ្រព្យសម្បត្តិផ្សេងៗសម្រាប់បម្រើឱ្យការអនុវត្តគម្រោង
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និងកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដើម្បីផ្សព្វផ្សាយឱ្យបានទូលាយ និងច្បាស់លាស់អំពីក្របខណ្ឌច្បាប់ នីតិវិធី គោលការណ៍ និងគោលនយោបាយដោះស្រាយផលប៉ះពាល់ដោយសារគម្រោង ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋរងផលប៉ះពាល់នៅតាមទីតាំងគម្រោងនីមួយៗ
- រៀបចំឱ្យមានយន្តការវាយតម្លៃដី និងទ្រព្យសម្បត្តិផ្សេងៗដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ដើម្បីជាមូលដ្ឋានសម្រាប់ទូទាត់សំណងឱ្យបានសមរម្យ និងយុត្តិធម៌ ជូនប្រជាពលរដ្ឋរងផលប៉ះពាល់
- ធ្វើការតាមដានត្រួតពិនិត្យផ្ទៃក្នុង លើការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍ ដើម្បីធានានូវអនុលោមភាព និងប្រសិទ្ធភាពនៃការអនុវត្តការងារ
- រៀបចំឱ្យមានការតាមដានត្រួតពិនិត្យពីខាងក្រៅដោយភ្នាក់ងារឯករាជ្យ ចំពោះអនុលោមភាពនៃការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម
- ចូលរួមជាមួយតំណាងក្រសួង ស្ថាប័នអនុវត្តគម្រោង និងអាជ្ញាធរដែនដីនៅពេលប្រគល់ទទួលគម្រោងដែលបានសាងសង់ ស្តារ ឬជួសជុលរួច ដើម្បីពិនិត្យផ្ទៀងផ្ទាត់លើការប្រើប្រាស់ជាក់ស្តែងនូវដី ឬទ្រព្យសម្បត្តិដែលត្រូវបានធ្វើលទ្ធកម្មសម្រាប់បម្រើឱ្យគម្រោង ហើយដែលបានប្រើប្រាស់ថវិកាជាតិ ឬថវិកាដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការនានា
- សហការជាមួយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋាន ឬអង្គភាពជំនាញនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអនុវត្តគម្រោង ក្នុងការរៀបចំឱ្យមានការចុះបញ្ជីដីធ្លីក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ចំពោះដីដែលបានធ្វើលទ្ធកម្មសម្រាប់គម្រោង និងដែលបានប្រគល់ជូនក្រសួង ស្ថាប័នអនុវត្តគម្រោង ដើម្បីកាន់កាប់ និងគ្រប់គ្រងបន្ត
- តំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីដែលមានបណ្តឹងតវ៉ាទៅតុលាការទាក់ទងនឹងការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ឬបញ្ហាទូទាត់សងសំណង ឬលក្ខណៈសម្បត្តិក្នុងការទទួលបាននូវប្រាក់សំណង និង/ឬប្រាក់ឧបត្ថម្ភផ្សេងៗ
- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងគ្រប់គ្រងទិន្នន័យផលប៉ះពាល់នៃគម្រោងនីមួយៗ ដែលទទួលបានពីក្រសួង ស្ថាប័នអនុវត្តគម្រោង

- រៀបចំសំណើថវិកាពេញលេញសម្រាប់ការសិក្សា ការរៀបចំ និងការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ដោយផ្អែកលើលទ្ធផលនៃការអង្កេតវាស់វែងលម្អិតអំពីផលប៉ះពាល់ និងលទ្ធផលនៃការសិក្សាវាយតម្លៃថ្លៃដី និងទ្រព្យសម្បត្តិផ្សេងៗដែលទទួលរងផលប៉ះពាល់
- សហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍
- សិក្សាស្រាវជ្រាវ រៀបចំ និងកសាងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងគោលនយោបាយដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍ ដោយមានការចូលរួមពីអង្គភាពពាក់ព័ន្ធ
- រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព របស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតអំពីក្របខណ្ឌច្បាប់ នីតិវិធី គោលការណ៍ និងគោលនយោបាយពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា ។

**មាត្រា ៤.-**

អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម៖

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ១
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ២
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ៣

អង្គការលេខរបស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

នាយកដ្ឋានកិច្ចការទូទៅបំពេញមុខងារជាសេនាធិការ ឱ្យអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ លើការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល ហិរញ្ញវត្ថុ ច្បាប់ និងផែនការ និងព័ត៌មានវិទ្យា ។

នាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យបំពេញមុខងារជាសេនាធិកាឱ្យអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ លើការងារត្រួតពិនិត្យផ្ទៃក្នុង ការងារគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យា និងការងារទទួលពិនិត្យពាក្យបណ្តឹងតវ៉ា និងទំនាក់ទំនងសាធារណៈ ។

នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ១ ទី ២ និង ទី ៣ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ លើការងារដោះស្រាយផលប៉ះពាល់ដល់ដីធ្លី សំណង់ផ្ទះសម្បែង សិទ្ធិ និងទ្រព្យសម្បត្តិផ្សេងៗដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា ។

ការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល

**មាត្រា ៦.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងហិរញ្ញប្បទានប្រតិបត្តិការ និងបំណុលរដ្ឋ ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាព។

**មាត្រា ៧.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល មានភារកិច្ចដូចតទៅ:

- រៀបចំ និងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានឥតសំណង ការទទួលហិរញ្ញប្បទានឥតសំណង ការឱ្យគេខ្ចីប្រាក់ ការខ្ចីប្រាក់ពីគេ ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗទៀត
- គ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ
- គ្រប់គ្រងបំណុលរបស់រដ្ឋ
- សហការជាមួយក្រសួង ស្ថាប័ន ក្នុងការត្រួតពិនិត្យ និងតាមដានលើការអនុវត្តនីតិវិធីចំណាយថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ និងថវិកាបដិភាគ
- ចូលរួមកសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- សហប្រតិបត្តិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុអន្តរជាតិជាមួយអង្គភាពពាក់ព័ន្ធ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូពាក់ព័ន្ធនានា ។

**មាត្រា ៨.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលមាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម:

- នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី
- នាយកដ្ឋានសហប្រតិបត្តិការពហុភាគី
- នាយកដ្ឋានគ្រប់គ្រងបំណុល
- នាយកដ្ឋានកិច្ចការទូទៅ

អង្គការលេខរបស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៩.-**

នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារសហប្រតិបត្តិការទ្វេភាគី ។

នាយកដ្ឋានសហប្រតិបត្តិការពហុភាគី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារសហប្រតិបត្តិការពហុភាគី ។

នាយកដ្ឋានគ្រប់គ្រងបំណុល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារគ្រប់គ្រងបំណុល ។

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារគ្រប់គ្រងទូទៅ ។

ការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ផ្នែកទី ៣
## នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន

**មាត្រា ១០.-**

នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកកម្មសវនកម្មបច្ចេកវិទ្យាព័ត៌មាន ។

អង្គការលេខរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រោយពីការបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ១១.-**

នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានភារកិច្ចដូចតទៅ:

- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យានៃអគ្គនាយកដ្ឋាន
- រៀបចំគោលការណ៍ ស្តង់ដា និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋាន
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ជំនាញសវនកម្មបច្ចេកវិទ្យាព័ត៌មានរយៈពេលវែង មធ្យម និងខ្លី
- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម និងផែនការសវនកម្មប្រចាំឆ្នាំនៃអគ្គនាយកដ្ឋាន
- ធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអង្គភាពទាំងឡាយក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន និងតាមដានការអនុវត្តអនុសាសន៍
- ធ្វើសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ (Financial Management Information System-FMIS) នៅតាមអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន និងតាមដានការអនុវត្តអនុសាសន៍សវនកម្ម ។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា ១២.-**

ប្រកាសពាក់ព័ន្ធនឹងការបង្កើត ឬការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងវិទ្យាស្ថាន និងអង្គភាពថ្នាក់មូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំពុងអនុវត្ត ត្រូវបន្តអានុភាពអនុវត្តរហូតដល់មានប្រកាសថ្មី របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

ត្រូវបានលុបបទប្បញ្ញត្តិមួយចំនួននៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម:

- ពាក្យ “ដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍” ក្នុងមាត្រាទី ១០ ត្រេទី ៣
- មាត្រាទី ១១ ត្រេទី ១៣ និងត្រេទី ១៤
- មាត្រាទី ១២ ត្រេទី ៥

- មាត្រាទី ១៣ កថាខណ្ឌទី ៥
- ពាក្យ "ហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋ" ក្នុងមាត្រាទី ១៨
- ពាក្យ "រួមទាំងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ" ក្នុងមាត្រាទី ១៩ ត្រែទី ៧
- មាត្រាទី ១៩ ត្រែទី ៩ ត្រែទី ១០ ត្រែទី ១១ និងត្រែទី ១៤
- មាត្រាទី ២០ ត្រែទី ៥
- មាត្រាទី ២១ កថាខណ្ឌទី ៥

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

<u>**កន្លែងទទួល:**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦

អង្គការលេខរបស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យលេខ.១១៥....អនក្រ.បក ចុះថ្ងៃទី ២៧... ខែ ឧសភា..ឆ្នាំ ២០១៦

អង្គការលេខរបស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យលេខ.១១៥.....អនក្រ.បក ចុះថ្ងៃទី ២៧... ខែមករា...ឆ្នាំ ២០១៦
អង្គការលេខរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

